**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# ប្រទេសកម្ពុជា៖ ក្រុមអ្នកជំនាញ អ.ស.ប មានប្រសាសន៍ថា ការជំនុំជម្រះក្តីរបស់លោក កឹម សុខា "មិនមានគុណភាពអាចទទួលយកបានឡើយ"

ទីក្រុងហ្សឺណែវ (១៧ មករា ២០២០) - ក្រុមអ្នកជំនាញសិទ្ធិមនុស្សអង្គការសហប្រជាជាតិ* បានសម្តែងកង្វល់អំពីការជំនុំជម្រះក្តីពីបទក្បត់ជាតិ ដែលបានបើកសវនាការក្នុងអាទិត្យនេះ ប្រឆាំងនឹងលោក កឹម សុខា មេដឹកនាំគណបក្សប្រឆាំងនៅកម្ពុជា ដោយក្រុមអ្នកជំនាញបានមានប្រសាសន៍ថា ដំណើរការទាំងមូលចាប់ពីការចោទប្រកាន់ រហូតដល់ ការជំនុំជម្រះក្តី គ្របដណ្តប់ដោយភាពមិនប្រក្រតី។

ក្រុមអ្នកជំនាញ មានប្រសាសន៍ថា "យើង មានហេតុផលរឹងមាំអាចជឿថាការចោទប្រកាន់ពីបទក្បត់ជាតិប្រឆាំងនឹងលោក សុខា គឺជាហេតុផលនយោបាយ ហើយការចោទប្រកាន់នេះវាក៏ជាផ្នែកនៃលំនាំមួយកាន់តែធំជាងនេះនៃការប្រើប្រាស់ច្បាប់មិនត្រឹមត្រូវ ដើម្បីដាក់គោលដៅទៅលើគូប្រជែងនយោបាយ និងអ្នករិះគន់រដ្ឋាភិបាល"។

លោក សុខា ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងចោទប្រកាន់ពីបទឃុបឃិតជាមួយបរទេស (ក្បត់ជាតិ) ទាក់ទងនឹងសុន្ទរកថាមួយដែលលោកបានថ្លែងនៅប្រទេសអូស្រ្តាលីក្នុងឆ្នាំ២០១៣ ដែលត្រូវបានចាក់ផ្សាយដោយបណ្តាញផ្សព្វផ្សាយកម្ពុជា (ស៊ីប៊ីអិន)។ ប្រសិនជាលោកត្រូវបានផ្តន្ទាទោសមែននោះ លោក កឹម សុខា ប្រឈមនឹងការជាប់ពន្ធនាគារពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ។

បន្ទាប់ពីការចាប់ខ្លួននៅខែកញ្ញា ឆ្នាំ២០១៧ លោក សុខា ត្រូវបានបដិសេធពាក្យសុំនៅក្រៅឃុំ និងត្រូវឃុំខ្លួនបណ្តោះអាសន្នរហូតដល់មានការដោះលែងដោយមានលក្ខខណ្ឌពីការឃុំខ្លួនក្នុងផ្ទះ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១៨។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ លោក សុខា ត្រូវបានដោះលែងដោយមានលក្ខខណ្ឌពីការឃុំខ្លួនក្នុងផ្ទះ។ លោកត្រូវបានហាមឃាត់មិនឲ្យធ្វើដំណើរទៅក្រៅប្រទេស ហើយត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយ។ ក្នុងមតិដែលបានសម្រេចក្នុងឆ្នាំ២០១៨ ក្រុមការងារអង្គការសហប្រជាជាតិស្តីពីការឃុំខ្លួនដោយបំពាន បានរកឃើញថាការឃុំខ្លួនបណ្តោះអាសន្នរបស់លោក កឹមសុខា គឺធ្វើឡើងដោយបំពាន។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ដំណើរការទាំងមូលនៃការចាប់ខ្លួន និងការឃុំខ្លួនរបស់លោក កឹម សុខា គឺមិនមានគុណភាពអាចទទួលយកបាន ដោយមានភាពមិនប្រក្រតី និងការមិនគិតគូរយ៉ាងច្បាស់ពីច្បាប់សិទ្ធិ

មនុស្សអន្តរជាតិ និងច្បាប់កម្ពុជា៉។ "លោក សុខា ត្រូវបានចាប់ខ្លួនដោយគ្មានដីកាចាប់ខ្លួន និងមិនគោរពអភ័យឯកសិទ្ធិសភារបស់លោក។ គាត់ត្រូវបានគេបដិសេធផងដែរ មិនឲ្យជួបមេធាវីនៅដំណាក់កាលដំបូងនៃការឃុំខ្លួន ហើយទីបំផុត លោកត្រូវបានឃុំខ្លួនឮបណ្ដោះអាសន្នអស់រយៈពេលមួយដែលលើសពីរយៈពេលអតិបរិមា ដែលច្បាប់កម្ពុជាអនុញ្ញាត៉ ។

ក្រុមអ្នកជំនាញ អ.ស.ប បានសម្ដែងកង្វល់យ៉ាងខ្លាំងចំពោះសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់មន្ត្រីជាន់ខ្ពស់មួយចំនួន ទាក់ទងនឹងករណីរបស់ លោក សុខា ដែលអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ និងអាចជះឥទ្ធិពលដល់លទ្ធផលនៃការជំនុំជម្រះរបស់លោក។ កង្វះការចូលរួមរបស់សាធារណៈជននៅបន្ទប់សវនាការ ដែលត្រូវបានអនុញ្ញាតិជាពិសេស សម្រាប់តែសមាជិកអង្គទូត ក៏អាចដាក់ជាសំណួរអំពីភាពត្រឹមត្រូវនៃការជំនុំជម្រះក្ដីរបស់លោកផងដែរ។

ក្រុមអ្នកជំនាញ អំពាវនាវម្ដងហើយម្ដងទៀតដល់អាជ្ញាធរជានាឲ្យមានយុត្តិធម៌សម្រាប់លោក សុខា ដកចេញជាបន្ទាន់នូវលក្ខខណ្ឌធានានៅក្រៅឃុំដែលមានការរិតត្បិត ផ្ដល់សិទ្ធិនយោបាយរបស់លោកឡើងវិញ និង ធានាសិទ្ធិរបស់លោកក្នុងការទទួលបានសំណង និងជួសជុលការខូចខាតផ្សេងទៀត។

**ចប់**

***(*) អ្នកជំនាញ អ.ស.ប៖ លោកស្រី សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *<u>អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា</u> លោក* ***ដាវីដ កាយេ*** *<u>អ្នករាយការណ៍ពិសេសស្ដីពីការលើកស្ទួយ និងការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ</u> និងលោក* ***ឌីហ្គោ កាសៀ-សាយយាន*** *អ្នករាយការណ៍ពិសេសស្ដីពី<u>ឯករាជ្យភាពរបស់ចៅក្រម និងមេធាវី។</u>*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជា<u>នីតិវិធីពិសេស</u>របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ(ប.ស. គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យផ្នែកសិទ្ធិមនុស្ស ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗនៅគ្រប់កន្លែងទាំងអស់លើពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អប ទេ ហើយធ្វើការ.ស.ងារដោយឯករាជ្យពីរដ្ឋាភិបាល និងអង្គការទាំងឡាយ។ ពួកគាត់បម្រើការងារក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីប្រទេសកម្ពុជា។*

*សិទ្ធិមនុស្ស អ ប ទំព័រប្រទេស៖.ស.ប្រទេសកម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖*
*អ្នកស្រី អ៊ីស្ទឺរ ឡាំ )Esther Lam) តាមរយៈទូរស័ព្ទលេខ៖ ៤១ ២២ ៩២៨ ៩១+)០៨ ឬ អ៊ីម៉ែល elam@ohchr.org) និង លោក ងន់ ស៊ីហេង តាមរយៈទូរស័ព្ទ៖ ១(០) ៨៥៥+)៧ ៨៧ ៥៦ ០៣ អ៊ីម៉ែល sngon@ohchr.org)*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អប សូមទាក់ទង៖.ស.*
*អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ ៤១ ២២ ៩១៧ ៩៣៨៣ ឬ+) អ៊ីម៉ែល jlaurence@ohchr.org)*

*សូមស្វែងយល់អំពីក្រុមអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យរបស់អ.ស.ប តាមដានទ្វីតធី @UN_SPExperts*

តើអ្នកមានកង្វល់អំពីពិភពលោកដែលយើងកំពុងរស់នៅមែនទេ?

**ដូច្នេះ ក្រោកឡើងដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ។**

#Standup4humanrights